# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃពុធ ៩ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ, ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មានស្តីពី
# ការដាក់ដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម
# តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី២

វិស័យបច្ចេកវិទ្យាឌីជីថល បានក្លាយទៅជាផ្នែកមួយដ៏សំខាន់នៃជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងបានផ្តល់នូវកាលានុវត្តភាពថ្មី ក្នុងការជំរុញសេដ្ឋកិច្ចជាតិឱ្យកាន់តែមានកំណើនធុរកិច្ច, បង្កើនប្រសិទ្ធភាព និងផលិតភាពខ្ពស់ និងធ្វើឱ្យបរិយាកាសប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិកាន់តែប្រសើរឡើងជាងមុន។ ឈរលើមូលដ្ឋានយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ១ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ កន្លងទៅ ដើម្បីផ្តល់ភាពងាយស្រួលដល់ធុរជនក្នុងការចុះបញ្ជីអាជីវកម្ម ដោយចំណាយពេលវេលា និងថវិកាតិចជាងមុន និងធ្វើឡើងជាកញ្ចប់តាមនីតិវិធីអនឡាញជាមួយក្រសួង-ស្ថាប័នចំនួន ៣ រួមមាន ក្រសួងពាណិជ្ជកម្ម, អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ក្រុមហ៊ុនដែលចង់ចុះបញ្ជីជាគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក៏អាចដាក់ស្នើតាមអនឡាញបាន ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ទៀតសោត ក្នុងដំណាក់កាលទី១នេះ ក៏មានកិច្ចសហការផ្តល់ទិន្នន័យបុគ្គលពីក្រសួងមហាផ្ទៃផងដែរ។

ដើម្បីបង្កើនបទពិសោធន៍ និងពង្រីកវិសាលភាពប្រើប្រាស់របស់ធុរជនឱ្យបានកាន់តែល្អនិងងាយស្រួលជាងមុនថែមមួយកម្រិតទៀត រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ដំណើរការជាផ្លូវការនូវ **"ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី២"** នាថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៩:០០ ព្រឹកក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ។ កម្មវិធីត្រូវបានចាក់ផ្សាយបន្តផ្ទាល់តាមរយៈទំព័រហ្វេសប៊ុករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របទៅតាមបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩។

នៅក្នុងដំណាក់កាលទី ២ នេះ ក្រសួង-ស្ថាប័នចូលរួមចំនួន ៤ បន្ថែមទៀត រួមមានក្រសួងឧស្សាហកម្ម វិទ្យា-សាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ ធុរជនអាចស្នើសុំ (១) ប្រកាសស្ដីពីការបង្កើតសហគ្រាសធុនតូចនិងមធ្យម (២) អាជ្ញា-បណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍ (៣) អាជ្ញាបណ្ណទេសចរណ៍សម្រាប់សណ្ឋាគារ-សេវាស្នាក់នៅទេសចរណ៍ (៤) អាជ្ញាបណ្ណទេសចរណ៍សម្រាប់ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ (៥) អាជ្ញា-បណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) (៦) អាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យប្រៃសណីយ៍ (៧) អាជ្ញាបណ្ណអាជីវកម្មបញ្ចាំ និង (៨) អាជ្ញាបណ្ណអាជីវកម្មប្រាតិភោគដោយអនុប្បទាន។

ដូចគ្នាទៅនឹងការចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី១ ដែរ, ធុរជនអាចស្នើសុំអាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ប្រកាសបង្កើតខាងលើ តាមអនឡាញ តាមរយៈគេហទំព័រ www.registrationservices.gov.kh ឬគេហទំព័រចុះបញ្ជីអាជីវកម្មរបស់ក្រសួង-ស្ថាប័នជំនាញ រួចចូលប្រើប្រាស់ (Login) ដោយប្រើគណនីកម្មវិធីទូរស័ព្ទ CamDigiKey, ធ្វើការបង់ប្រាក់អនឡាញ និងទទួលបាននូវអាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ប្រកាសបង្កើតជាទម្រង់ឌីជីថលដែលមានសុពលភាពស្របច្បាប់ពេញលេញ និងអាចយកទៅប្រើប្រាស់ជាផ្លូវការបាន។ ក្នុងករណីដែលធុរជនបានធ្វើការចុះបញ្ជីអាជីវកម្មក្រោយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ តាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មាន ជាមួយក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងដំណាក់កាលទី១ ឬផតថលរួម (Single Portal) រួចហើយ, ធុរជននឹងមិនចាំបាច់វាយបញ្ចូលព័ត៌មានដែលធ្លាប់បានវាយបញ្ចូលហើយក្នុងផតថលរួម (Single Portal) នៅដំណាក់កាលទី ១ ទៀតនោះទេ ធុរជនគ្រាន់តែវាយបញ្ចូលលេខសម្គាល់អត្តសញ្ញាណសហគ្រាស (Single ID) ដែលទទួលបានពី Single Portal នោះព័ត៌មានដែលធ្លាប់បានបញ្ចូលក្នុងការចុះបញ្ជីកន្លងមក នឹងបង្ហាញលើពាក្យស្នើសុំនៃដំណាក់កាលទី២ ដោយស្វ័យប្រវត្តិ។

រយៈពេលត្រួតពិនិត្យលើពាក្យស្នើសុំនីមួយៗ ត្រូវបានកាត់បន្ថយ និងកំណត់ដូចខាងក្រោម ៖

| **ក្រសួង-ស្ថាប័ន** | **អាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ ប្រកាសបង្កើត** | **រយៈពេល ត្រួតពិនិត្យចាស់** | **រយៈពេល ត្រួតពិនិត្យថ្មី** |
|---|---|---|---|
| **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេក-វិទ្យា និងនវានុវត្តន៍** | ប្រកាសស្តីពីការបង្កើតសហគ្រាសធុនតូច និងមធ្យម | ១៥ ថ្ងៃនៃ ថ្ងៃធ្វើការ | ៣ ថ្ងៃនៃ ថ្ងៃធ្វើការ |
| **ក្រសួងទេសចរណ៍** | - អាជ្ញាបណ្ណទេសចរណ៍សម្រាប់ការីទេសចរណ៍ និងភ្នាក់ងារទេសចរណ៍<br>- អាជ្ញាបណ្ណទេសចរណ៍សម្រាប់សណ្ឋាគារ និងសេវាស្នាក់នៅទេសចរណ៍<br>- អាជ្ញាបណ្ណទេសចរណ៍សម្រាប់ | ២៨ ថ្ងៃនៃ ថ្ងៃធ្វើការ | ៧ ថ្ងៃនៃ ថ្ងៃធ្វើការ |

| | | | |
|---|---|---|---|
| | ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ | | |
| **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | - ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន(ICT)<br>- ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យប្រៃសណីយ៍ | ៣០ ថ្ងៃនៃថ្ងៃធ្វើការ | ៧ ថ្ងៃនៃថ្ងៃធ្វើការ |
| **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** | - អាជ្ញាបណ្ណអាជីវកម្មបញ្ចាំ<br>- អាជ្ញាបណ្ណអាជីវកម្មប្រាតិភោគដោយអនុប្បទាន | ៣០ ថ្ងៃនៃថ្ងៃធ្វើការ | ៧ ថ្ងៃនៃថ្ងៃធ្វើការ |

គួរបញ្ជាក់ផងដែរថា ប្រតិបត្តិការស្វ័យប្រវត្តិនៃការទាញយកទិន្នន័យរបស់ក្រុមហ៊ុន/សហគ្រាសពីថ្នាលដំណាក់កាលទី១ មកថ្នាលដំណាក់កាលទី២ ជាសមិទ្ធផលនៃការផ្លាស់ប្ដូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមរយៈថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា (CamDX)។ ការណ៍នេះ មិនត្រឹមតែបង្កើនបទពិសោធន៍នៃការប្រើប្រាស់ឱ្យកាន់តែមានលក្ខណៈងាយស្រួលជាងមុន សម្រាប់ធុរជនក្នុងការបំពេញពាក្យស្នើសុំតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាបច្ច័យវិជ្ជមានដែលអនុញ្ញាតឱ្យក្រសួង-ស្ថាប័នអាចកាត់បន្ថយរយៈពេលត្រួតពិនិត្យពាក្យស្នើសុំ និងធានាបានថាទិន្នន័យរបស់ក្រុមហ៊ុន/សហគ្រាសនៅគ្រប់ក្រសួង-ស្ថាប័នមានសង្គតិភាពផងដែរ។ សមិទ្ធផលនេះ គឺជាការបោះជំហានដ៏សំខាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចបាននូវចក្ខុវិស័យកសាងសង្គម និងសេដ្ឋកិច្ចឌីជីថលដ៏រស់រវើក ដោយប្រើប្រាស់បច្ចេកវិទ្យាជាស្នូលនៃការអនុវត្តការងារ។

ជាមួយនឹងការតម្រង់ទិស និងការយកចិត្តទុកដាក់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ២ ជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអន្តរក្រសួងរៀបចំការចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងមានការចូលរួមយ៉ាងសស្រាក់សស្រាំ និងកិច្ចសហការដែលមិនអាចខ្វះបានរបស់ក្រសួង-ស្ថាប័នចូលរួម ដូចជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងទេសចរណ៍ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ។ ជាជំហានបន្ទាប់, ក្រុមការងារនឹងបន្តអភិវឌ្ឍទៅលើថ្នាលបច្ចេកវិទ្យាព័ត៌មាននេះជាមួយក្រសួង-ស្ថាប័នជំនាញបន្ថែមទៀត ដើម្បីជាក់ឱ្យដំណើរការនូវដំណាក់កាលបន្ទាប់ ដែលអនុញ្ញាតឱ្យធុរជនអាចស្នើសុំអាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ប្រកាសបង្កើតតាមជំនាញផ្សេងៗទៀត នាពេលអនាគតបានផងដែរ ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

Phnom Penh, September 1, 2021

# PRESS RELEASE
## The Official Launch of the Business Registration System on Information Technology Platform Phase 2

Digital technology has become an integral part of our daily life and has offered new opportunities in leveraging the national economic growth by bringing in businesses, increasing efficiency and productivity, and promoting economic competitiveness. Under the attentive supervision of **Samdech Akka Moha Sena Padei Techo HUN Sen, Prime Minister of the Kingdom of Cambodia,** the Business Registration System on Information Technology Platform (OBR) Phase 1 was officially launched on June 15, 2020 with the aim of easing the business registration process through time and fees reduction, and shifting to online, packaged registration procedure with the Ministry of Commerce, the General Department of Taxation, and the Ministry of Labour and Vocational Training. Additionally, companies can be registered as a Qualified Investment Project online, with the Council for the Development of Cambodia. In this Phase 1 too, the Ministry of Interior also participated in sharing individual's data.

To enhance the quality of user experience and to expand the scope, the OBR Phase 2 was officially launched on September 1, 2021 at 9am, presiding over by **His Excellency Dr. AUN Pornmoniroth, Deputy Prime Minister, Minister of Economy and Finance**. Due to the Covid-19 pandemic, the event was virtually lived on the "Ministry of Economy and Finance" Facebook page. Collaborated with the Ministry of Industry, Science, Technology and Innovation, the Ministry of Tourism, the Ministry of Posts and Telecommunications and the Non-Banking Financial Services Authority, through the OBR Phase 2, users can apply for: (1) Prakas to Establish Small and Medium Enterprise, (2)

Tour Operator and Travel Agent Tourism License, (3) Hotel and Accommodation Service Tourism License, (4) Restaurant Tourism License, (5) License/Certificate/Permit to Operate in ICT Sector, (6) License/Certificate/Permit to Operate in Post Sector, (7) Pawn Business License, and (8) Transfer-of-Title Business License.

Similar to the OBR Phase 1, users can now apply for specialized licenses online. To be able to apply, users need to visit www.registrationservices.gov.kh or the websites of the relevant ministries/institutions, login by using the CamDigiKey mobile application, pay online, and obtain a legally-valid, digital license/certificate/permit/Prakas. Users who have registered their business after June 15, 2020 through the OBR Phase I portal (also known as Single Portal), are not required to fill information that they used to fill on the Single Portal. Once input the Single ID of the company or enterprise obtained from the Single Portal, information will be automatically filled out on the Phase 2 application. Furthermore, the review period has been reduced and set as follows:

| **Ministries/ Institutions** | **Licenses/Certificates/ Permit/Prakas** | **Review period prior to OBR Phase 2** | **Review period for OBR Phase 2** |
|---|---|---|---|
| **Ministry of Industry, Science, Technology and Innovation** | - Prakas to Establish Small and Medium Enterprise | 15 working days | 3 working days |
| **Ministry of Tourism** | - Tour Operator and Travel Agent Tourism License<br>- Hotel and Accommodation Service Tourism License<br>- Restaurant Tourism License | 28 working days | 7 working days |
| **Ministry of Post and Communications** | - License/Certificate/Permit to Operate in ICT Sector<br>- License/Certificate/Permit to Operate in Post Sector | 30 working days | 7 working days |
| **Non-Bank Financial Services Authority** | - Pawn Business License<br>- Transfer-of-Title Business License | 30 working days | 7 working days |

The spontaneous data exchange between OBR Phase 1 and Phase 2 is made possible by the data exchange between relevant ministries/institutions on the Cambodia Data Exchange Platform (CamDX). This does not only foster better user experience in filling out the application form but also stands as the positive feature that allows relevant ministries/institutions to reduce the review period and to ensure data consistency across relevant ministries/institutions. This is a crucial course of action taken by the Royal Government of Cambodia, in realizing the vision of building a vibrant digital society and economy by using technology as a core of the implementation.

The official launch of Online Business Registration Phase 2 would not be possible without the attentive orientation and supervision of **His Excellency Dr. AUN Pornmoniroth, Deputy Prime Minister, Minister of Economy and Finance** and the collective efforts of the inter-ministerial working group and the vigorous participation of the participating ministries, namely the Ministry of Industry, Science, Technology and Innovation, the Ministry of Tourism, the Ministry of Post and Telecommunications and the Real Estate Business and Pawnshop Regulator of the Non-Bank Financial Services Authority. For the next step, the working group will continue to work with other relevant ministries/institutions to further expand the scope of the OBR platform to later phases by enabling users to apply for other specialized licenses in the near future.